**Embassy of Japan**
**in the Kingdom of Cambodia**

# Press Release

No. 02 PR-20/EoJ 10 January 2020

## JENESYS 2019 Youth Exchange Program (Culture)

25 Cambodian youths are going to visit Japan from 13 to 21 January 2020 at the invitation of the Ministry of Foreign Affairs of Japan under the JENESYS (Japan-East Asia Network of Exchange for Students and Youth) 2019.

These participants were selected by "The Competition for Participating JENESYS 2019 Youth Exchange Program to Japan" among 488 applicants of 122 groups through the first screening by the Embassy of Japan and the second round of the group presentation competition by 48 university students of 12 groups, which was held on 17 October 2019 at the Cambodia-Japan Cooperation Center (CJCC) under the theme of "**My Province, My Hometown**".

The participants will visit Tokushima prefecture, which is the host town for Cambodian athletes during the Tokyo Olympic and Paralympic games in 2020 and famous for Awa Odori, one of the biggest traditional dance festival in Japan. During their visit to Tokushima Prefecture, they will try Awa Odori dance and join an exchange program with Japanese university students. They will also pay a courtesy call on Governor of Tokushima Prefecture and experience homestay as well as Japanese culture. The detailed schedule is attached herewith.

The JENESYS aims to promote mutual trust and understanding among the people of Japan and other participating countries and to build a basis for future friendship and cooperation. Through the program, the Ministry of Foreign Affairs has invited more than 2,100 Cambodian youths since 2007.

It is expected that the participants will deepen their understanding of Japan and after coming back, share their experience widely with Cambodian people.

# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
# សេចក្តីប្រកាសព័ត៌មាន

No. 02 PR-20/EoJ ថ្ងៃទី១០ ខែមករា ឆ្នាំ២០២០

## កម្មវិធីផ្លាស់ប្តូរយុវជន JENESYS 2019
## (វប្បធម៌)

តាមរយៈការអញ្ជើញរបស់ក្រសួងការបរទេសជប៉ុន យុវជនកម្ពុជាចំនួន២៥រូប នឹងធ្វើដំណើរទស្សនកិច្ចទៅកាន់ប្រទេសជប៉ុនចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ ក្រោមកម្មវិធីបណ្តាញផ្លាស់ប្តូរសិស្សនិស្សិត និងយុវជនរវាងប្រទេសជប៉ុន និងបណ្តាប្រទេសអាស៊ីខាងកើត ដែលហៅកាត់ថា JENESYS 2019។

អ្នកចូលរួមទាំងអស់ត្រូវបានជ្រើសរើស ដោយវគ្គជម្រុះដំបូងក្នុងចំណោមបេក្ខជនដាក់ពាក្យសរុប ៤៨៨រូប ស្មើនឹង១២២ក្រុម និងវគ្គប្រកួតផ្តាច់ព្រ័ត្រ មានបេក្ខជន សរុបចំនួន៤៨រូប ស្មើនឹង១២ក្រុម ដែលបានធ្វើបទបង្ហាញក្រោមប្រធានបទ «ស្រុកកំណើតខ្ញុំ» កាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៩ នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន (CJCC)។

អ្នកចូលរួម នឹងទៅទស្សនកិច្ចនៅខេត្តតុគឹស៊ីម៉ា ដែលជាខេត្តម្ចាស់ផ្ទះទទួលក្រុមកីឡាករជម្រើសជាតិកម្ពុជាចូលរួមការប្រកួតកីឡាអូឡាំពិក និងប៉ារ៉ាឡាំពិកតូក្យូ២០២០ និងមានរបាំប្រពៃណីដ៏ល្បីប្រចាំតំបន់គឺអាវ៉ាអូដូរី។ កំឡុងពេលទស្សនកិច្ចនៅតុគឹស៊ីម៉ា ពួកគាត់នឹងសាកល្បងរាំរបាំអាវ៉ាអូដូរី និងចូលរួមកម្មវិធីផ្លាស់ប្តូរជាមួយនឹងនិស្សិតសាកលវិទ្យាល័យនៅទីនោះ។ ពួកគាត់ ក៏នឹងចូលជួបសម្តែងការគួរសមជាមួយនឹងអភិបាលខេត្តតុគឹស៊ីម៉ា ព្រមទាំងទទួលយកបទពិសោធន៍ស្នាក់នៅផ្ទះជនជាតិជប៉ុន និងវប្បធម៌ជប៉ុនផងដែរ។ សូមមើលតារាងព័ត៌មានលម្អិតស្តីពីកាលបរិច្ឆេទដែលមានភ្ជាប់។

កម្មវិធីJENESYS មានគោលបំណងជម្រុញការយល់ដឹង និងការកសាងទំនុកចិត្តទៅវិញទៅមកក្នុងចំណោមប្រជាជនជប៉ុន និងបណ្តាប្រទេសចូលរួម និងដើម្បីកសាងមូលដ្ឋានគ្រឹះនៃកិច្ចសហប្រតិបត្តិការ និងចំណងមិត្តភាពនាពេលអនាគត។ តាមរយៈកម្មវិធីនេះ ក្រសួងការបរទេសជប៉ុនបានអញ្ជើញយុវជនកម្ពុជាចំនួនជាង២១០០នាក់ហើយតាំងពីឆ្នាំ២០០៧មក។

យើងខ្ញុំសង្ឃឹមថាអ្នកចូលរួមនឹងអាចយល់ដឹងអំពីប្រទេសជប៉ុនកាន់តែស៊ីជម្រៅថែមទៀត ព្រមទាំងចែករំលែកនូវបទពិសោធន៍របស់ខ្លួនឲ្យបានទូលំទូលាយទៅកាន់ប្រជាជនកម្ពុជា បន្ទាប់ពីវិលត្រលប់មកវិញ។